ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០១៥/ ... ២០០៧

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការណែនាំអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ

## រដ្ឋមន្ត្រីក្រសួងការពារជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពី ការកែសំរួល តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តនីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដើម្បីធានាអោយការអនុវត្តនីបានត្រឹមត្រូវ និងមានប្រសិទ្ធភាពចំពោះផលប្រយោជន៍ពាក់ព័ន្ធទៅនឹងអតីតភាពការងាររបស់យោធិនគ្រប់ៗរូប ។

## សម្រេច

## ជំពូកទី១

## ការកំណត់ទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់ធ្វើការណែនាំលំអិត ក្នុងការអនុវត្តនីរបបសោធននិវត្តន៍ និងរបបសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ សំដៅអនុវត្តច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ព្រមទាំងអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តនីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ។

**ប្រការ២.-**

ដើម្បីអនុវត្តប្រកាសនេះ ពាក្យខាងក្រោមត្រូវបានកំណត់និយមន័យដូចតទៅ ÷

**-យោធិនអាជីព** គឺជានាយទាហាន នាយទាហានរង ឬបុគ្គលិកសមានកម្ម ដែលត្រូវបានទទួលអោយចូលជាយោធិនអាជីព ក្រោយពីបានធ្វើពាក្យសុំចូល ហើយបានតែងតាំងឋានន្តរសក្តិតាមឋានានុក្រម ។

**-របបសោធននិវត្តន៍** គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់ៗរូបត្រូវទទួលបាន ក្រោយពេលបញ្ចប់ការងារក្នុងកងយោធពលខេមរភូមិន្ទ ដោយផ្អែកទៅលើលក្ខខណ្ឌឋានន្តរសក្តិ អាយុ និងលក្ខខណ្ឌរយៈពេលបំរើការងារ ។

**-របបបាត់បង់សមត្ថភាពការងារ** គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់ៗរូបត្រូវទទួលបានក្រោយពេលបញ្ចប់ការងារក្នុងកងយោធពលខេមរភូមិន្ទ អាស្រ័យដោយសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមកមានផលប៉ះពាល់សុខភាព ដែលមិនអាចបំពេញការងារទៀតបាន ហើយត្រូវដាក់ចូលក្នុងប្រភេទបាត់បង់សមត្ថភាពការងារ ។

**-របបចេញពីជួរ** គឺជាគោលរបបគិតជាទឹកប្រាក់ ដែលយោធិនគ្រប់ៗរូបត្រូវទទួលបាន ក្រោយពេលបញ្ចប់ការងារនៅក្នុងកងយោធពលខេមរភូមិន្ទ ដែលមិនបានទទួលរបបសោធននិវត្តន៍ និងរបបបាត់បង់សមត្ថភាពការងារ ។

# ជំពូកទី២

## ការកំណត់ អំពីការដាក់អោយចូលនិវត្តន៍ និង របៀបគណនា

**ប្រការ៣.-**

យោធិនទាំងពីរភេទ ត្រូវដាក់អោយចូលនិវត្តន៍**តាមការកំណត់** ដោយមានលក្ខខណ្ឌឋានន្តរសក្តិ និង លក្ខខណ្ឌអាយុ ដូចមានចែងខាងក្រោម ÷

**ក-នាយទាហាន :**

| | | |
|---|---|---|
| ១-ថ្នាក់វរសេនីយ៍ឯក | និងវរនាវីឯកឡើងទៅ | នៅពេលដល់អាយុ ៦០ឆ្នាំ |
| ២-ថ្នាក់វរសេនីយ៍ទោ | និងវរនាវីទោ | នៅពេលដល់អាយុ ៥៨ឆ្នាំ |
| ៣-ថ្នាក់វរសេនីយ៍ត្រី | និងវរនាវីត្រី | នៅពេលដល់អាយុ ៥៥ឆ្នាំ |
| ៤-ថ្នាក់អនុសេនីយ៍ឯក | និងអនុនាវីឯក | នៅពេលដល់អាយុ ៥៣ឆ្នាំ |
| ៥-ថ្នាក់អនុសេនីយ៍ទោ | និងអនុនាវីទោ | នៅពេលដល់អាយុ ៤៨ឆ្នាំ |
| ៦-ថ្នាក់អនុសេនីយ៍ត្រី | និងអនុនាវីត្រី | នៅពេលដល់អាយុ ៤៦ឆ្នាំ |
| ៧-ថ្នាក់នាយចំណង់ | និងនាយនាវីចំណង់ | នៅពេលដល់អាយុ ៤៣ឆ្នាំ |

**ខ-នាយទាហានរង :**

| | | |
|---|---|---|
| ១-ថ្នាក់ព្រិន្ទបាលឯក | និងនាយចក្របាលឯក | នៅពេលដល់អាយុ ៤២ឆ្នាំ |
| ២-ថ្នាក់ព្រិន្ទបាលទោ | និងនាយចក្របាលទោ | នៅពេលដល់អាយុ ៤១ឆ្នាំ |
| ៣-ថ្នាក់ពលបាលឯក | និងចក្របាលឯក | នៅពេលដល់អាយុ ៤០ឆ្នាំ |
| ៤-ថ្នាក់ពលបាលទោ | និងចក្របាលទោ | នៅពេលដល់អាយុ ៣៩ឆ្នាំ |
| ៥-ថ្នាក់ពលបាលត្រី | និងចក្របាលត្រី | នៅពេលដល់អាយុ ៣៨ឆ្នាំ |

**ប្រការ៤.-**

យោធិនទាំងពីរភេទ ត្រូវដាក់អោយចូលនិវត្តន៍បាន**មុនពេលកំណត់** ដោយមិនគិតពីលក្ខខណ្ឌឋានន្តរសក្តិ មិនគិតពីលក្ខខណ្ឌអាយុ សាមីយោធិនត្រូវធ្វើពាក្យស្នើសុំចូលនិវត្តន៍មុនពេលកំណត់ ដោយមានការឯកភាពទទួលស្គាល់តាមឋានានុក្រម មកក្រសួងការពារជាតិ ។

**ប្រការ៥.-**

ការកំណត់អំពី រយៈពេលបំរើការងារ :

**ក-រយៈពេលបំរើការងាររួម :**

រយៈពេលបំរើការងាររួម គឺជារយៈពេលដែលយោធិនទាំងពីរភេទ បានបំរើការងារកងទ័ពផង និងស៊ីវិលផង ឬបានបំរើកងទ័ពតាមរបបសង្គមនីមួយៗ បូករួមនឹងរយៈពេលបំរើកងយោធពលខេមរភូមិន្ទបច្ចុប្បន្ន រហូតដល់ថ្ងៃចូលនិវត្តន៍ ។

ដោយឡែក ចំពោះអ្នកដែលធ្លាប់បានបំរើការងាររដ្ឋមុនឆ្នាំ១៩៧៥ ហើយពុំបានបំរើការងារក្នុងរបបប៉ុល ពត ក៏ត្រូវបានគិតបន្ថែមរយៈពេលបំរើការងារ ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ថែមទៀតដែរ ។

**ខ-រយៈពេលបំរើការងារបន្តបន្ទាប់ ឬជាប់រហូត :**

-រយៈពេលបំរើការងារបន្តបន្ទាប់ គឺគិតចាប់ពីថ្ងៃដែលយោធិនបានចូលបំរើក្នុងជួរកងទ័ព រហូតបង្កើតបានជាកងយោធពលខេមរភូមិន្ទ ដល់ថ្ងៃចូលនិវត្តន៍ ។

-ក្នុងចន្លោះពេលទៅសម្រាកច្បាប់ ព្យាបាលរោគ ទៅរៀនសូត្រក្នុង ឬក្រៅប្រទេស ដោយមានការចាត់តាំង រយៈពេលជាប់មន្ទីរឃុំឃាំងដោយគ្មានទោសកំហុស រយៈពេលជាប់ជាឈ្លើយសឹកខ្មាំង ដោយរក្សាបាននូវការសម្ងាត់ និងស្មោះត្រង់ចំពោះប្រទេសជាតិ ត្រូវបានគិតជារយៈពេលបំរើការងារជាប់រហូត ។

**គ-រយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព :**

-តំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព លុះត្រាតែបានបំរើការងារនោះជាប់រហូត ហើយបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

-រយៈពេលបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពស៊ីវិល "បើមាន" ត្រូវបានគិតរួមជាមួយរយៈពេលទៅបន្តការងារតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ក្នុងកងយោធពលខេមរភូមិន្ទ ។

-ក្នុងចន្លោះពេលទៅសម្រាកច្បាប់ ទៅរៀនសូត្រ ឬទៅព្យាបាលរោគ (រយៈពេលពី ៦ខែចុះ) ក៏ត្រូវចាត់ទុកជារយៈពេលប៉ះពាល់សុខភាពជាប់រហូតដែរ ។

**ឃ-រយៈពេលបំរើការងារអតីតភាព :**

ការគិតរយៈពេលបំរើការងារអតីតភាពតាមរបបសង្គមនីមួយៗ និងការគិតអតីតភាព គិតចាប់តាំងពីពេលមានចលនាតស៊ូ រហូតដល់ថ្ងៃបង្កើតអង្គការមួយជាផ្លូវការ ហើយបានចូលរួមក្នុងរាជរដ្ឋាភិបាលរហូតដល់បច្ចុប្បន្ននេះ គិតស្មើនឹងរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ។

**ប្រការ៦.-**

របៀបគណនារបបសោធននិវត្តន៍ :

**ក-របបអាទិភាព :**

-យោធិនទាំងពីរភេទ ដែលបានបំរើការងារកងទ័ពមុនថ្ងៃទី១៨ មិនា ឆ្នាំ១៩៧០ ជាប់រហូតដល់ថ្ងៃចូលនិវត្តន៍ ឬវីរជនដែលមានគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ត្រូវបានទទួលរបបអាទិភាព ២០ភាគរយ នៃបៀវត្សរ៍ហានន្តរសក្តិថែមទៀត ។

-យោធិនទាំងពីរភេទ ដែលបានបំរើការងារកងទ័ពមុនថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ ជាប់រហូតដល់ថ្ងៃចូលនិវត្តន៍ ឬបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានទទួលរបបអាទិភាព ១៥ភាគរយ នៃបៀវត្សរ៍ហានន្តរសក្តិថែមទៀត ។

របបអាទិភាពដូចមានរៀបរាប់ខាងលើនេះ និវត្តជនត្រូវបានរបបអាទិភាពណាមួយដែលខ្ពស់ជាងគេ មិនអាចទទួលបានទាំងពីរ ឬទាំងបីបានឡើយ ។

**ខ-របបសោធននិវត្តន៍អប្បបរមា :**

យោធិនទាំងពីរភេទ ដែលត្រូវបានទទួលរបបសោធននិវត្តន៍អប្បបរមាគឺ :

-យោធិនដែលបានដាក់អោយចូលនិវត្តន៍**តាមការកំណត់** និងយោធិនដែលបានដាក់អោយចូលនិវត្តន៍**មុនពេលកំណត់** ត្រូវមានរយៈពេលបំរើការងារក្នុងកងទ័ពជាប់រហូតនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព យ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។ ចំពោះយោធិនដែលបំរើការងារមិនប៉ះពាល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវមានរយៈពេលបំរើការងាររួម ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និង ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

-ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែ ស្មើ ៥០ ភាគរយ នៃបៀវត្សរ៍ហានន្តរសក្តិប្រចាំខែចុងក្រោយ ។ ប្រាក់នេះ ត្រូវបានអត្រាបន្ថែមមួយឆ្នាំ ២ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបំរើការងារកងទ័ព ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំរើការងាររដ្ឋ តែសរុបមិនត្រូវលើស ៨០ ភាគរយ នៃប្រាក់សោធននិវត្តន៍អតិបរមាឡើយ ។

**គ-របបសោធននិវត្តន៍អតិបរមា :**

-យោធិនទាំងពីរភេទ ដែលត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ជាយោធិនដែលដាក់អោយចូលនិវត្តន៍**តាមការកំណត់** ត្រូវមានរយៈពេលបំរើការងារក្នុងកងទ័ពជាប់រហូតនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ការងារប៉ះពាល់សុខភាព យ៉ាងតិច ១៥ (ដប់ប្រាំ)ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ១២(ដប់ពីរ)ឆ្នាំ ចំពោះនារី ។ ចំពោះយោធិនដែលបំរើការងារមិនប៉ះពាល់ សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ ត្រូវមានរយៈពេលបំរើការងាររួម លើសពី ២០ (ម្ភៃ)ឆ្នាំ ចំពោះបុរស និង លើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

-ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទ ដែលមានលក្ខខណ្ឌទទួលរបបសោធននិវត្តន៍អប្បបរមា ឬយោធិនពិការបំរើការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ។

ប្រាក់សោធននិវត្តន៍អប្បបរមា ឬប្រាក់សោធននិវត្តន៍អតិបរមាខាងលើនេះ មិនអាចតិចជាងប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមាប្រចាំខែរបស់នាយទាហានឡើយ ក្នុងករណីទាបជាង ត្រូវតម្លើងអោយស្មើ ។

**ឃ**-ក្រៅពីទទួលរបបឧបត្ថម្ភផ្សេងៗ យោធិនទាំងពីរភេទនៅបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹង ៨ខែ នៃប្រាក់បៀវត្សរ៍ប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

**ង**-យោធិនទាំងពីរភេទ ដោយពុំបានបំពេញលក្ខខណ្ឌ ដូចមាននៅក្នុងចំណុច (ខ) (គ) ខាងលើនេះ រដ្ឋមិនផ្តល់របបសោធននិវត្តន៍ឡើយ ករណីនេះ រដ្ឋឧបត្ថម្ភប្រាក់មួយលើកគត់ ស្មើនឹងបៀវត្សរ៍សរុបចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំនៃរយៈពេលបំរើការងារ ប៉ុន្តែប្រាក់នេះ មិនត្រូវតិចជាងប្រាក់បៀវត្សរ៍ ៦ខែ របស់សាមីខ្លួនឡើយ ។

**ច-រូបមន្តគណនាប្រាក់សោធននិវត្តន៍ :**

| ស.ន | = (ប + ឧ + ម + ត + ម្ហូប) × % |
|---|---|

| | |
|---|---|
| ស.ន | = ប្រាក់សោធននិវត្តន៍ប្រចាំខែ |
| ប | = ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ |
| ឧ | = ប្រាក់ឧបត្ថម្ភលើបៀវត្សឋានន្តរសក្តិ |
| ម | = ប្រាក់បំណាច់មុខងារ "បើមាន" |
| ត | = ប្រាក់បំណាច់តំបន់ "បើមាន" |
| ម្ហូប | = ប្រាក់ម្ហូប ( មិនគិតបញ្ចូលថ្លៃអង្ករ) |
| % | = ចំនួនភាគរយ |

ប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហាន ត្រូវបានបូកជាមួយប្រាក់ឧបត្ថម្ភ ៩០ ភាគរយលើប្រាក់បៀវត្សរ៍ឋានន្តរសក្តិ និងបូកជាមួយប្រាក់ហូបថែមទៀត ។

ក្រៅពីរបបសោធននិវត្តន៍ផ្ទាល់ខ្លួនខាងលើ នៅបានទទួលរបបផ្សេងៗទៀត មានដូចខាងក្រោម ÷

-ប្រាក់អាទិភាព

-ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភកូន ។

**ឆ-ឧទាហរណ៍ជាក់ស្តែង :**

**ឧទាហរណ៍ទី១ :** លោកអនុសេនីយ៍ទោនៃកងទ័ពជើងគោកម្នាក់ មានអាយុ ៤៥ឆ្នាំ មានរយៈពេលបំរើការងារប៉ះពាល់សុខភាពក្នុងកងទ័ព ចំនួន ១០ឆ្នាំ មានកូន ២នាក់ ។ លោកត្រូវបានចូលនិវត្តន៍មុនពេលកំណត់ និងបានទទួលរបបសោធននិវត្តន៍អប្បបរមា ។

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៤០.៤០០៛

-ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៤០.៤០០៛ + \left(\frac{៤០.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១២១.៧៦០៛$$

-អត្រាបន្ថែម ២%

២% × ៧ = ១៤%

៥០% + ១៤% = ៦៤%

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១២១.៧៦០៛ \times ៦៤}{១០០} = ៧៧.៩២៦.៤៛$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ទោ ត្រូវមកទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៥០}{១០០}\right) + ៤៥\ ០០០៛\right] = ១០៦.៥៦០៛$$

-ប្រាក់អាទិភាព ១៥% = ៦.០៦០៛

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាកឧបត្ថម្ភកូន = ៥.០០០៛

∗ ប្រាក់សោធននិវត្តន៍ប្រចាំខែ = **១២០.៦២០៛**

**ឧទាហរណ៍ទី២ :** លោកអនុសេនីយ៍ឯកម្នាក់ មានអាយុ ៥៥ឆ្នាំ មានរយៈពេលបំរើការងាររដ្ឋរួម ២១ឆ្នាំ ក្នុងនោះ ស៊ីវិល ១៦ឆ្នាំ និងកងទ័ព ៥ឆ្នាំ មានកូន ២នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលរបបសោធននិវត្តន៍អប្បបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៤៤.៤០០៛

∗ ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៤៤.៤០០៛ + \left(\frac{៤៤.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១២៥.៣៦០៛$$

-អត្រាបន្ថែម ២% :

+ស៊ីវិល = ២% × ១១ = ២២%

+កងទ័ព = ២% × ២ = ៤%

+សរុប = ២៦%

-ប្រាក់សោធននិវត្តន៍អប្បបរមា = ៥០% + ២៦% = ៧៦%

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១២៩.៣៦០៛ \times ៧៦}{១០០} = ៩៨.៣១៣៛$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ឯកត្រូវមកទទួលបៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ ។

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន = ៥.០០០៛

∗ ប្រាក់សោធននិវត្តន៍ប្រចាំខែ = ១១៤.៥៦០៛

**ឧទាហរណ៍ទី៣ :** លោកវរសេនីយ៍ទោម្នាក់ មានអាយុ ៥៨ឆ្នាំ មានរយៈពេលបំរើការងារកងទ័ពជាប់រហូតដល់ថ្ងៃចូលនិវត្តន៍បានចំនួន ២៩ឆ្នាំ ក្នុងនោះ ចូលបំរើកងទ័ពមុនឆ្នាំ១៩៧០ បាន ៥ឆ្នាំ លោកបានរត់ទៅតស៊ូក្នុងព្រៃបាន ៩ឆ្នាំ និងបានចូលបំរើកងទ័ពរហូតដល់ថ្ងៃចូលនិវត្តន៍បាន ១៥ឆ្នាំទៀត ។ លោកមានកូន ៣នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៥៨.៥០០៛

∗ ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៥៨.៥០០៛ + \left(\frac{៥៨.៥០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១៥៦.១៥០៛$$

-ប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន :

$$\frac{១៥៦.១៥០៛ \times ៨០}{១០០} = ១២៤.៩២០៛$$

-ប្រាក់អាទិភាព ( មុនឆ្នាំ១៩៧០) ២០% = ១១.៧០០៛

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន = ៧.៥០០៛

∗ ប្រាក់សោធននិវត្តន៍ប្រចាំខែ = ១៤៧.១២០៛

**ឧទាហរណ៍ទី៤ :** លោកអនុសេនីយ៍ត្រីម្នាក់ មានអាយុ ៤៦ឆ្នាំ មានរយៈពេលបំរើការងារប៉ះពាល់សុខភាពក្នុងកងទ័ពជាប់រហូត ចំនួន ១៥ឆ្នាំ ។ លោកមានកូន ចំនួន ៣នាក់ លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ និងត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៣៦.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[\text{៣៦.៤០០៛} + \left(\frac{\text{៣៦.៤០០៛} \times \text{៩០}}{\text{១០០}}\right) + \text{៤៥.០០០៛}\right] = \text{១១៤.១៦០៛}$$

-ប្រាក់សោធននិវត្តន៍អតិបរមា :

$$\frac{\text{១១៤.១៦០៛} \times \text{៨០}}{\text{១០០}} = \text{៩១.៣២៨៛}$$

-ប្រាក់នេះតិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកអនុសេនីយ៍ត្រី ត្រូវមកទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[\text{៣២.៤០០៛} + \left(\frac{\text{៣២.៤០០៛} \times \text{៩០}}{\text{១០០}}\right) + \text{៤៥.០០០៛}\right] = \text{១០៦.៥៦០៛}$$

| | | |
|---|---|---|
| -ប្រាក់អាទិភាព ១៥% | = | ៥.៤៦០៛ |
| -ប្រាក់ឧបត្ថម្ភគ្រួសារ | = | ៣.០០០៛ |
| -ប្រាក់ឧបត្ថម្ភកូន | = | ៧.៥០០៛ |
| * ប្រាក់សោធននិវត្តន៍ប្រចាំខែ | = | ១២២.៥២០៛ |

**ឧទាហរណ៍ទី៥ :** លោកពលបាលឯកម្នាក់ មានអាយុ ៤២ឆ្នាំ មានរយៈពេលបំរើការងារក្នុងកងទ័ព ២០ឆ្នាំ មានកូន ២នាក់ ។

លោកត្រូវបានចូលនិវត្តន៍តាមការកំណត់ ហើយត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា :

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ =២៦.៤០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[\text{២៦.៤០០៛} + \left(\frac{\text{២៦.៤០០៛} \times \text{៩០}}{\text{១០០}}\right) + \text{៤៥.០០០៛}\right] = \text{៩៥.១៦០៛}$$

-ប្រាក់សោធននិវត្តន៍អតិបរមា

$$\frac{\text{៩៥.១៦០៛} \times \text{៨០}}{\text{១០០}} = \text{៧៦.១២៨៛}$$

-ប្រាក់នេះ តិចជាងប្រាក់អប្បបរមារបស់នាយទាហាន ដូច្នេះ លោកពលបាលឯក ត្រូវមកទទួលប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\left[\text{៣២.៤០០៛} + \left(\frac{\text{៣២.៤០០៛} \times \text{៩០}}{\text{១០០}}\right) + \text{៤៥.០០០៛}\right] = \text{១០៦.៥៦០៛}$$

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន = ៥.០០០៛

* ប្រាក់សោធននិវត្តន៍ប្រចាំខែ = ១១៤.៥៦០៛

## ជំពូកទី៣

## ការកំណត់ អំពីការអោយទទួលបាត់បង់សមត្ថភាពការងារ និង របៀបគណនា

**ប្រការ៧.-**

យោធិនទាំងពីរភេទ ដែលត្រូវទទួលបាត់បង់សមត្ថភាពការងារ លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម ÷

**ក-ការកំណត់អំពី ការដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដោយមិនស្ថិតក្នុងភារកិច្ច :**

គឺជាយោធិនចាស់ជរា មានជម្ងឺរ៉ាំរ៉ៃ ឬទទួលគ្រោះថ្នាក់ផ្សេងៗ តែមិនបាត់បង់សរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិនពិការ លុះត្រាតែបានបំរើការងាររដ្ឋរួម យ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ១០ (ដប់)ឆ្នាំ ចំពោះនារី ។ រយៈពេល ១៥ (ដប់ប្រាំ)ឆ្នាំ និង ១០ (ដប់)ឆ្នាំ ខាងលើនេះ ត្រូវមានរយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ យ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ជាបន្តបន្ទាប់ មុនពេលទទួលបាត់បង់សមត្ថភាពការងារ ។

-រយៈពេលបំរើការងារ ត្រូវបានកំណត់ដូចមានចែងក្នុងជំពូកទី២ ប្រការ៥ នៃប្រកាសនេះ ។

**ខ-ការកំណត់អំពី ការដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដោយសារភារកិច្ច :**

គឺជាយោធិនដែលបានបំពេញភារកិច្ច ឬធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដោយពុំគិតពីអាយុ ឬរយៈពេលបំរើការងាររដ្ឋរួមឡើយ ហើយត្រូវបានទទួលបាត់បង់សមត្ថភាពការងារតាមការកំណត់កំរិតបាត់បង់សមត្ថភាពការងារជាបីថ្នាក់ ដូចខាងក្រោម :

-ថ្នាក់ទី១ បាត់បង់សមត្ថភាពការងារលើសពី ៨០ ភាគរយ

-ថ្នាក់ទី២ បាត់បង់សមត្ថភាពការងារលើសពី ៦០ ភាគរយ

-ថ្នាក់ទី៣ បាត់បង់សមត្ថភាពការងារលើសពី ៤០ ភាគរយ

លក្ខខណ្ឌនៃការកំណត់កំរិតថ្នាក់បាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទ ត្រូវបានកំណត់ដូចមានចែងក្នុងជំពូកទី៣ មាត្រាទី១៣ នៃអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ។

**គ**-យោធិនទាំងពីរភេទ ដែលបានដាក់អោយទទួលបាត់បង់សមត្ថភាពការងារ ដូចមានចែងក្នុងចំណុច (ក) (ខ)ខាងលើ ត្រូវបានទទួលរបបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ចែកជាពីរផ្នែកដូចខាងក្រោម ÷

១-របបសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ស្មើនឹង ៥០ ភាគរយ នៃបៀវត្សរ៍ឋានន្តរសក្តិចុងក្រោយ ត្រូវបានផ្តល់ចំពោះ ÷

-យោធិនដែលបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច (ក) ខាងលើ

-យោធិនដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវមានរយៈពេលបំរើការងារចំនួន ១០ (ដប់) ឆ្នាំ ចំពោះបុរស និង ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែស្មើ ៤០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិប្រចាំខែចុងក្រោយ ត្រូវបានអត្រាបន្ថែមមួយឆ្នាំ ១.៥ ភាគរយទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេល បំរើការងារកងទ័ព ឬចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំរើការងាររដ្ឋរម ។ តែប្រាក់សរុបមិនត្រូវលើស ៦០ ភាគរយ នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ ។

**២-ប្រាក់សោធនបាត់បង់សមត្ថភាពការងារ :**

-យោធិនបាត់បង់សមត្ថភាពការងារក៏រិតថ្នាក់ទី១ ទទួលបាន ១០០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន និងត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែមសម្រាប់អ្នកជំនួយកិច្ចការក្នុងផ្ទះ ស្មើនឹងប្រាក់បៀវត្សរ៍ប្រចាំខែយុទ្ធជនម្នាក់ ។

-យោធិនបាត់បង់សមត្ថភាពការងារក៏រិតថ្នាក់ទី២ ទទួលបាន ៨០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

-យោធិនបាត់បង់សមត្ថភាពការងារក៏រិតថ្នាក់ទី៣ ទទួលបាន ៦០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន ។

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារទាបបំផុត មិនត្រូវតិចជាង ៤០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិអប្បបរមារបស់នាយទាហានឡើយ ក្នុងករណីទាបជាង ត្រូវតម្លើងអោយស្មើ ។

-យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ត្រូវបានអត្រាបន្ថែម ១៥ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិថែមទៀត ។

-ចំពោះវីរជននៃកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលអត្រាបន្ថែម ១០ ភាគរយ នៃបៀវត្សរ៍ឋាននូរសក្តិថែមទៀត ។

**ឃ**-ក្រោយពីដាក់អោយទទួលបាត់បង់សមត្ថភាពការងារ យោធិនទាំងពីរភេទ នៅបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹង ៦ខែ នៃបៀវត្សរ៍ឋាននូរសក្តិចុងក្រោយរបស់សាមីខ្លួនបន្ថែមទៀត ។

**ង**-យោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដែលមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុង ចំណុច (ក) (ខ) ខាងលើនេះ រដ្ឋមិនផ្តល់របបសោធនបាត់បង់សមត្ថភាពការងារឡើយ ។ ករណីនេះ រដ្ឋឧបត្ថម្ភប្រាក់មួយលើកគត់ ស្មើនឹងបៀវត្សរ៍ចុងក្រោយរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំរើការងារ ប៉ុន្តែទឹកប្រាក់នេះមិនត្រូវតិចជាងប្រាក់បៀវត្សរ៍ ៦ខែ របស់សាមីខ្លួនឡើយ ។

**ច-រូបមន្តគណនាប្រាក់សោធនបាត់បង់សមត្ថភាពការងារ :**

| ស.ប. = (ប + ឧ + ម + ត + ម្ហូប) × % |
|---|

ស.ប = ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ

ប = ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ

ឧ = ប្រាក់ឧបត្ថម្ភលើបៀវត្សឋានន្តរសក្តិ

ម = ប្រាក់បំណាច់មុខងារ "បើមាន"

ត = ប្រាក់បំណាច់តំបន់ "បើមាន"

ម្ហូប = ប្រាក់ម្ហូប ( មិនគិតបញ្ចូលថ្លៃអង្ករ)

% = ចំនួនភាគរយ

ប្រាក់បៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហាន ត្រូវបានបូកជាមួយប្រាក់ឧបត្ថម្ភលើប្រាក់បៀវត្សរ៍ឋានន្តរសក្តិ បូកប្រាក់បំណាច់មុខងារ ប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ជំនាញ បូកនឹង ប្រាក់ម្ហូប ។ ក្រៅពីរបបបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួនខាងលើនេះ នៅបានទទួលរបបផ្សេងៗ ដូចខាងក្រោម :

-ប្រាក់អាទិភាព

-ប្រាក់ឧបត្ថម្ភគ្រួសារ និងប្រាក់ឧបត្ថម្ភកូន ។

**ឆ-ឧទាហរណ៍ជាក់ស្តែង :**

**ឧទាហរណ៍ទី១ :** លោកនាយចំណង់ម្នាក់ បានរងគ្រោះថ្នាក់ផ្ទាល់ខ្លួន មិនអាចបន្តការងារទៀតបាន ។ លោកមានរយៈពេលបំរើការងាររដ្ឋរួមចំនួន ១៥ឆ្នាំ ក្នុងនោះស៊ីវិល ១០ឆ្នាំ និងកងទ័ព ៥ឆ្នាំ ។ គាត់មានកូន ១នាក់ នៅក្នុងបន្ទុក ។

លោកត្រូវទទួលបាត់បង់សមត្ថភាពការងារ ដោយពុំមែនបំពេញភារកិច្ច នឹងត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ៥០% ។

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៣២.៤០០៛

✱ ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៣២.៤០០៛ + \left(\frac{៣២.៤០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១០៦.៥៦០៛$$

-អត្រាបន្ថែម ១.៥%

+ស៊ីវិល = ១.៥% × ៥ = ៧.៥%

+កងទ័ព = ១.៥% × ២ = ៣ %

✱ សរុប =១០.៥%

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន

៥០% + ១០.៥% = ៦០.៥%

ប្រាក់នេះ មិនត្រូវលើសពី ៦០%ឡើយ ដូច្នេះត្រូវទទួល ៦០%វិញ :

$$\frac{១០៦.៥៦០៛ \times ៦០}{១០០} = ៦៣.៩៣៦៛$$

ដូចនេះ ត្រូវមកទទួលប្រាក់ ៩០% នៃបៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\frac{១០៦.៥៦០៛ \times ៩០}{១០០} = ៩៥.៩០៤៛$$

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

-ប្រាក់ឧបត្ថម្ភកូន ១នាក់ = ២.៥០០៛

∗ ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = **១០១.៤០៤៛**

**ឧទាហរណ៍ទី២ :** លោកវរសេនីយ៍ឯកម្នាក់ មានរយៈពេលបំរើការងារ ១៥ឆ្នាំ លោកបានទទួលរងគ្រោះថ្នាក់ក្រឡាប់រថយន្តដោយការងារផ្ទាល់ខ្លួន ហើយមិនអាចបំរើការងារបានទៀតឡើយ ។ គាត់មានកូន ២នាក់ ។

លោកត្រូវបានទទួលបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី២ ។

លោកត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ៥០%

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៦៤.៩០០៛

∗ ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៦៤.៩០០៛ + \left(\frac{៦៤.៩០០៛ \times ៩០}{១០០}\right) + ៤៥.០០០៛\right] = ១៦៧.៥៥០៛$$

-អត្រាបន្ថែម

១.៥% × ១២ = ១៨%

៥០% + ១៨% = ៦៨%

∗ ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន :

-ប្រាក់នេះ មិនត្រូវលើសពី ៦០% ទេ

$$\frac{១៦៧.៥៥០៛ \times ៦០}{១០០} = ១០០.៥៣០៛$$

+ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

+ប្រាក់ឧបត្ថម្ភកូន២នាក់ = ៥.០០០៛

∗ ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = **១០៨.៥៣០៛**

**ឧទាហរណ៍ទី៣ :** លោកពលបាលត្រីម្នាក់ បំរើការងារនៅតំបន់លំបាកជាប់របួតដល់មានជម្ងឺ មិនអាចបន្តការងារទៀតបាន ។

លោកត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី២ ។

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ២៤.៥០០៛

* ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[២៤.៥០០៛ + \left(\frac{២៤.៥០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ៩១.៩៥០៛$$

-ប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន

$$\frac{៩១.៩៥០៛ \times ៦០}{១០០} = ៥៥.១៧០៛$$

ដូច្នេះ ត្រូវមកទទួលប្រាក់ ៩០% នៃបៀវត្សរ៍ឋានន្តរសក្តិអប្បបរមារបស់នាយទាហានវិញ :

$$\frac{១០៦.៥៦០៛ \times ៩០}{១០០} = ៩៥.៩០៤៛$$

-ប្រាក់អាទិភាព ១៥% = ៣.៦៧៥៛

-ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ = ១០២.៥៧៩៛

**ឧទាហរណ៍ទី៤ :** លោកវរសេនីយ៍ត្រីម្នាក់ បានរងគ្រោះថ្នាក់ក្នុងពេលដោះមីន ។ លោកមានកូន ២នាក់ ។ លោកត្រូវទទួលបាត់បង់សមត្ថភាពការងារកំរិតថ្នាក់ទី១ ។

-ប្រាក់បៀវត្សរ៍ឋានន្តរសក្តិ = ៥៤.៥០០៛

-ប្រាក់ប្រចាំខែផ្ទាល់ខ្លួន :

$$\left[៥៤.៥០០៛ + \left(\frac{៥៤.៥០០៛ \times ៥០}{១០០}\right) + ៤៥.០០០៛\right] = ១៤៨.៨៥០៛$$

+ប្រាក់អាទិភាព ១៥% = ៨.១៧៥៛

+ប្រាក់ឧបត្ថម្ភគ្រួសារ = ៣.០០០៛

+ប្រាក់ឧបត្ថម្ភកូន = ៥.០០០៛

+ប្រាក់អ្នកជំនួយការងារម្នាក់ = ៨៦.៨០០៛

* ប្រាក់សោធនបាត់បង់សមត្ថភាពការងារ = ២៥១.៥២៥៛

## ជំពូកទី៤

## ការកំណត់ អំពីនីតិវិធី និង គំរូបែបបទសំណុំលិខិត

ប្រការ៨.-

នាយទាហាន នាយទាហានរង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ត្រូវបំពេញបែបបទស្តីពីជីវប្រវត្តិពិស្តារ តាមគំរូនៃ "ឧបសម្ព័ន្ធទី១" ។ ចំពោះការណែនាំលំអិតអំពីការសរសេរជីវប្រវត្តិពិស្តារនេះ នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ជាអ្នកណែនាំផ្ទាល់ ។

**ប្រការ៩.-**

ជារៀងរាល់ឆ្នាំ ស្ថាប័នជំនាញ (នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា) ត្រូវស្រង់ឈ្មោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដែលត្រូវដាក់អោយចូលនិវត្តន៍តាមការកំណត់ និងត្រូវដាក់អោយចូលនិវត្តន៍មុនពេលកំណត់ ព្រមទាំងយោធិនដែលត្រូវទទួលបាត់បង់សមត្ថភាពការងារ និងយោធិនដែលត្រូវដាក់អោយចេញពីជួរ ស្របតាមផែនការប្រចាំឆ្នាំ ដើម្បីត្រៀមបំរុងមាន :

ក-ការស្នើសុំថវិកាឧបត្ថម្ភមួយលើក

ខ-ការស្នើសុំថវិកាធ្វើដំណើរ ហូបចុក ចំពោះអ្នកមានច្បាប់ឈប់សម្រាក

គ-ការធ្វើតំរោងប៉ាន់ស្មាន អំពីថវិកាប្រចាំខែ

**ប្រការ១០.-**

យោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ នឹងទទួលបានការជូនដំណឹងក្នុងរយៈពេល ១២ខែ ជាមុន ដើម្បីប្រុងប្រៀបកិច្ចការផ្សេងៗមាន :

ក-ការប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ក្រោយពេលចាកចេញពីកងយោធពលខេមរភូមិន្ទ ដោយអាចអនុញ្ញាតឈប់សម្រាកច្បាប់តាមការកំណត់ ដូចខាងក្រោម :

| | | |
|---|---|---|
| -ថ្នាក់ព្រិន្ទបាលឯកចុះ | ត្រូវបានឈប់សម្រាក | ៦ខែ |
| -ថ្នាក់នាយចំណង់ និងអនុសេនីយ៍ | ត្រូវបានឈប់សម្រាក | ៨ខែ |
| -ថ្នាក់វរសេនីយ៍ | ត្រូវបានឈប់សម្រាក | ១០ខែ |
| -ថ្នាក់ឧត្តមសេនីយ៍ ឬវីរជន | ត្រូវបានឈប់សម្រាក | ១២ខែ |

នៅពេលឈប់សម្រាកច្បាប់ក្នុងប្រទេស ត្រូវទទួលបានប្រាក់ធ្វើដំណើរ ប្រាក់ហូបចុកតាមផ្លូវ ទាំងទៅទាំងមក ។

ខ-ការបំពេញសំណុំលិខិតទទួលរបបសោធននិវត្តន៍ ។

គ-ការបំពេញបែបបទសុំបន្តការងារ ចំពោះយោធិនដែលមានវិន័យ គុណសម្បត្តិ សមត្ថភាព និងសុខភាពល្អ ឬជាអ្នកជំនាញឯកទេស ផ្អែកតាមតម្រូវការចាំបាច់របស់កងឯកភាព អាចស្នើសុំបន្តការងារមកក្រសួងការពារជាតិ ក្នុង ១ឆ្នាំម្តងៗ ។ រយៈពេលសុំបន្តការងារនេះ មិនត្រូវលើសពី ៥ឆ្នាំឡើយ ។

-រយៈពេលនៃការសុំបន្តការងារនេះ យោធិននៅទទួលបាន :

-សិទ្ធិទទួលបៀវត្សរ៍ ដូចក្នុងស្ថានភាពសកម្ម

-រយៈពេលបំរើការងារបន្ត ត្រូវបានគិតក្នុងអតីតភាព ដើម្បីទទួលរបបសោធននិវត្តន៍អតិបរមា ឬអប្បបរមា ។

-ចំពោះការជូនដំណឹង គំរូបែបបទនៃការស្នើសុំឈប់សម្រាក ការបំពេញសំណុំលិខិតទទួលរបបសោធននិវត្តន៍ ការបំពេញសំណុំលិខិតទទួលរបបសោធនបាត់បង់សមត្ថភាពការងារ ការបំពេញសំណុំលិខិតទទួលរបបឧបត្ថម្ភចេញពីជួរ និងការបំពេញបែបបទសុំបន្តការងារ នោះនាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ជាអ្នកអនុវត្ត និងធ្វើការណែនាំលំអិតតាមគំរូនៃ "ឧបសម្ព័ន្ធទី២" ។

## ជំពូកទី៥

## ការកំណត់ អំពីសមត្ថកិច្ចពាក់ព័ន្ធ និង ការធានាផ្សេងៗ

ដោយរដ្ឋមិនទាន់អាចធានា ចំពោះការបង្កើតបេឡាសោធនរបស់កងទ័ពបាន ហេតុនេះ ក្នុងកាលៈទេសៈបណ្តោះអាសន្ន ការធានាថវិកាឧបត្ថម្ភមួយលើក ការធានាថវិកាពេលឈប់សម្រាកច្បាប់ ត្រូវពឹងផ្អែកទៅលើការស្នើសុំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រីឯថវិកាប្រចាំខែ និងការគ្រប់គ្រង ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ ត្រូវបានប្រគល់អោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់គ្រងបន្តសិន ។

ដើម្បីមានមូលដ្ឋានអនុវត្តមុនពេលបង្កើតបេឡាសោធន ប្រការខាងក្រោមត្រូវបានចែង÷

**ប្រការ១១.-**

ក្រសួងការពារជាតិ ធានាបើកផ្តល់ប្រាក់ឧបត្ថម្ភមួយលើក ជូនដល់យោធិនស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ និងមុខសញ្ញាបាត់បង់សមត្ថភាពការងារ មុនពេលផ្ទេរប្រគល់ការធានាបើកផ្តល់បន្តទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងបើកប្រាក់ឧបត្ថម្ភមួយលើក ចំពោះមុខសញ្ញាយោធិនចេញពីជួរ មុនពេលចាកចេញពីកងយោធពលខេមរភូមិន្ទ និងបើកផ្តល់ប្រាក់ធ្វើដំណើរ ហូបចុក ចំពោះយោធិនស្ថិតក្នុងមុខសញ្ញាសោធននិវត្តន៍ ដែលបានអនុញ្ញាតឈប់សម្រាក ច្បាប់ ក្នុងរយៈពេលប្រុងប្រៀបជីវភាព ដូចមានចែងក្នុងប្រការ១០ ចំណុច (ក) នៃប្រកាសនេះ ។

**ប្រការ១២.-**

ដើម្បីធានាបានការផ្ទេរប្រគល់និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ព្រមទាំងធានាបានការប្រែប្រួល ក្រោយពេលផ្ទេរប្រគល់ទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាយកដ្ឋានសោធននិវត្តន៍ នៃ អគ្គនាយកដ្ឋានយោធសេវា ត្រូវធ្វើបែបបទនៃការផ្ទេរ និងបែបបទតាមដានការប្រែប្រួល ចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ សំដៅផ្សាភ្ជាប់ រហូតបង្កើតបានបេឡាសោធនរបស់កងទ័ព តាមគំរូបែបបទនៃ "ឧបសម្ព័ន្ធទី៣" ។

**ប្រការ១៣.-**

និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលគ្មានគ្រួសារជាទីបង្អែក រដ្ឋទទួលបន្ទុកអោយស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ។

ប្រាក់សោធនប្រចាំខែ ត្រូវបានកាត់ស្មើ ៥០ ភាគរយ ដើម្បីធានាការហូបចុក បើខ្វះខាត រដ្ឋបំពេញបន្ថែម ។

ចំពោះយោធិនបាត់បង់សមត្ថភាពការងារក៏រិតថ្នាក់ទី១ ប្រសិនបើទៅរស់នៅក្នុងមណ្ឌលចិញ្ចឹមរបស់រដ្ឋប្រាក់ឧបត្ថម្ភ សម្រាប់អ្នកបម្រើផ្ទាល់ រដ្ឋមិនបានបើកផ្តល់អោយឡើយ ។

**ប្រការ១៤.-**

និវត្តជន និងជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្លៀកពាក់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទ ក្នុងពិធីបុណ្យជាតិផ្សេងៗ ។

## ជំពូកទី៦
## ការកំណត់បញ្ចប់

**ប្រការ១៥.-**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៦.-**

អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការកងឯកភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ់

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ថ្នាក់ដឹកនាំក្រសួងការពារជាតិ
-ទីប្រឹក្សាក្រសួងការពារជាតិ
-អគ្គបញ្ជាការដ្ឋាន
-ដូចប្រការ១៦
(ដើម្បីជូនជ្រាប និងអនុវត្ត)
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ